ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីជាសះស្បើយចំនួន ០២នាក់ និងមិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី
# នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖ គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០២០ មានដូចតារាងខាងក្រោមនេះ ៖**

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា' | ៤១ | ១៩ | ២២ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.២. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣២២ | ៦៨ | ២៥៤ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | សរុបអ្នកមានវីរុសកូវីដ-១៩ | ៣៦៣ | ៨៧ | ២៧៦ | អ្នកឆ្លងថ្មី៖ ០នាក់ |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា' | ៣១ | ១៣ | ១៨ | អ្នកជាសះស្បើយថ្មី៖០១នាក់ |
| | ២.២. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣១៦ | ៦៥ | ២៥១ | អ្នកជាសះស្បើយថ្មី៖០១នាក់ |
| | សរុបអ្នកព្យាបាលជាសះស្បើយ | ៣៤៧ | ៧៨ | ២៦៩ | អ្នកជាសះស្បើយថ្មី៖០២នាក់ |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៣.១. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១ | ០៦ | ០៥ | |
| | ៣.២. មណ្ឌលសុខភាពចាក់អង្រែ | ០២ | ០១ | ០១ | |
| | ៣.៣. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង និងហង់សិន | ០៣ | ០២ | ០១ | |
| | សរុបអ្នកកំពុងសម្រាកព្យាបាល | ១៦ | ០៩ | ០៧ | |

## ២. ព័ត៌មានប្រចាំថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

**ក. ករណីជាសះស្បើយ ៖ សរុប ចំនួន ០២នាក់ មានដូចខាងក្រោម៖**

ក.១.ករណីជាសះស្បើយ៖ចំនួន ០១នាក់ ដែលជាអ្នកពាក់ព័ន្ធទៅនឹង ព្រឹត្តិការណ៍ សហគមន៍ ២៨វិច្ឆិកា



ទីស្តីការក្រសួងសុខាភិបាលដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

- ស្ត្រីជនជាតិខ្មែរអាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅបុរី លឹម ឈាងហាក់ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

**ក.២. ករណីជាសះស្បើយ៖ ចំនួន ០១នាក់ ជាអ្នកដំណើរចូលមកកម្ពុជា (ដែលមិនមានពាក់ព័ន្ធទៅនឹង 'ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា')**

-បុរសជនជាតិខ្មែរ អាយុ ៧៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាអ្នកដំណើរមកពីប្រទេសចិន តាមជើងហោះហើរ មកដល់កម្ពុជានៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

**ខ. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០២០

**គ. លទ្ធផលធ្វើតេស្តអ្នកប៉ះពាល់ក្នុង " ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា "**

វត្ថុសំណាកនៅសល់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ចំនួន ២៣សំណាក និងវត្ថុសំណាកនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២០ ចំនួន ២១៣សំណាក សរុបមានចំនួនទាំងអស់ ២៣៦សំណាក ដែលនៅក្នុងចំនួននេះ មានចំនួន ១៣៣ សំណាក ត្រូវបានធ្វើវិភាគដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ គឺមានលទ្ធផល អវិជ្ជមានវីរុសកូវីដ-១៩ ទាំងអស់។ ដោយឡែក មាននៅសល់វត្ថុសំណាកចំនួន ១០៣សំណាកទៀត ដែលត្រូវធ្វើវិភាគបន្តនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ (ដោយសារវត្ថុសំណាកទាំងនេះ ទទួលបានក្រោយម៉ោង ១៧:០០នាទីល្ងាចនៃថ្ងៃដដែល)។

សរុបអ្នកជំងឺកូវីដ-១៩ ដែលបានរកឃើញពាក់ព័ន្ធ "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា" ពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ មានចំនួន ៤១នាក់ (ស្រី ១៩នាក់ និងប្រុស ២២នាក់) ដែលនៅក្នុងចំនួននេះ មានអ្នកជាសះស្បើយ សរុបចំនួន ៣១នាក់ (ស្រី ១៣នាក់ និងប្រុស ១៨នាក់)។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ឌីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ៨កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០